ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ៩១៧ MIH / 2014

# ប្រកាស
## ស្តីពី
## នីតិវិធី និងបែបបទនៃការស្នើសុំនាំចូលឧបករណ៍មាត្រាសាស្ត្រ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រ
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញប្រកាសលេខ ១៨១ MIH/2014 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

### សម្រេច

**ប្រការ១._**

ប្រកាសនេះ មានគោលដៅកំណត់ យន្តការ និងវិធានគ្រប់គ្រងការនាំចូលឧបករណ៍មាត្រាសាស្ត្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២._**

ប្រកាសនេះមានគោលបំណង ៖

- ធានាឱ្យការធ្វើពាណិជ្ជកម្ម សេវាកម្ម មានភាពយុត្តិធម៌ និងត្រឹមត្រូវ
- ជំរុញឱ្យការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ស្របតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់
- ធានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់



ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខៈ (៨៥៥)២៣ ២១១ ៧៧៥
ទូរសារលេខៈ (៨៥៥) ២៣ ៤២៨ ២៦៣
អ៊ីមែល: mih.smcabinet@gmail.com

- ធ្វើឱ្យមានជំនឿចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីធានាសុខភាព សុវត្ថិភាព និងបរិស្ថាន។

**ប្រការ៣._**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើបុគ្គលដែលនាំចូលឧបករណ៍មាត្រាសាស្ត្រ សម្រាប់សកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម អាជីវកម្ម និង/ឬ វិស័យផ្សេងទៀត ដោយអនុលោមតាមច្បាប់ស្តីពីមាត្រាសាស្ត្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤._**

វាក្យស័ព្ទសំខាន់ៗ ប្រើសម្រាប់ក្នុងប្រកាសនេះ មានដូចតទៅ ៖

**ឧបករណ៍មាត្រាសាស្ត្រ** សំដៅដល់ ឧបករណ៍ទម្ងន់ និងរង្វាស់រង្វាល់ដែលបម្រើឱ្យវិស័យមាត្រាសាស្ត្រ។

**ពាណិជ្ជកម្ម** សំដៅដល់ ទំនាក់ទំនង ឬ កិច្ចសន្យា កិច្ចព្រមព្រៀង ការលក់ ការទិញ យោងតាមមាត្រា១៩ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ និងរាប់បញ្ចូលទាំងការវេចខ្ចប់ទំនិញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**អ្នកស្នើសុំ** សំដៅដល់ បុគ្គលដែលចុះហត្ថលេខាលើពាក្យស្នើសុំ។

**អ្នកនាំចូល** សំដៅដល់ បុគ្គលដែលបានអនុញ្ញាតឱ្យនាំចូលនូវឧបករណ៍មាត្រាសាស្ត្រ។

**បុគ្គល** សំដៅដល់ នីតិបុគ្គល ឬ រូបវន្តបុគ្គល។

**ពាក្យស្នើសុំ** សំដៅដល់ ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ជាសំណើផ្លូវការដោយលាយលក្ខណ៍អក្សររបស់អ្នកស្នើសុំ ដើម្បីទទួលបាននូវសិទ្ធិលើការនាំចូលឧបករណ៍មាត្រាសាស្ត្រ ដូចមានទម្រង់ដែលកំណត់ក្នុងប្រកាសនេះ។

**លិខិតអនុញ្ញាត** សំដៅដល់ លិខិតគតិយុត្តដែលអនុញ្ញាតឱ្យបុគ្គលដែលនាំចូល ឬ មានបំណងនាំចូលឧបករណ៍មាត្រាសាស្ត្រ ជាលាយលក្ខណ៍អក្សរដោយក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ឯកសារតម្រូវ** សំដៅដល់ ឯកសារពាក់ព័ន្ធនានាដែលតម្រូវឱ្យមានភាពអនុលោមជាមួយលក្ខខណ្ឌដែលបានកំណត់ក្នុងប្រកាសនេះ ។

**មន្ត្រីមានសមត្ថកិច្ច** សំដៅដល់ មន្ត្រីរាជការរបស់មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**នាយកដ្ឋានទទួលបន្ទុក** សំដៅដល់ នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រនៃមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ។

**រដ្ឋមន្ត្រី** សំដៅដល់ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥._**

រាល់ឧបករណ៍មាត្រាសាស្ត្រ អាចអនុញ្ញាតឱ្យនាំចូល សម្រាប់សកម្មភាពពាណិជ្ជកម្ម ឧស្សាហកម្ម សេវាកម្ម អាជីវកម្ម និង/ឬ វិស័យផ្សេងៗទៀត ដូចមានចែងក្នុងច្បាប់ស្តីពីមាត្រាសាស្ត្រ ត្រូវមានលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៦._**

រាល់នាំចូលឧបករណ៍មាត្រាសាស្ត្រ ត្រូវបំពេញបែបបទស្នើសុំ នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម រៀងរាល់ម៉ោងនៃថ្ងៃធ្វើការ។

ឯកសារតម្រូវរួមមាន ៖

១. ពាក្យស្នើសុំ

២. សម្រង់ព័ត៌មាន ឬ រូបភាពនៃគំរូឧបករណ៍មាត្រាសាស្ត្រដែលត្រូវនាំចូល

៣. បញ្ជីរាយឈ្មោះឧបករណ៍មាត្រាសាស្ត្រដែលត្រូវនាំចូល។

**ប្រការ៧._**

លក្ខខណ្ឌនៃឧបករណ៍មាត្រាសាស្ត្រ ដែលត្រូវអនុញ្ញាតឱ្យនាំចូលគឺ ៖

- មានភាពត្រឹមត្រូវ និងសមមូល ឬស្របទៅតាមប្រព័ន្ធឯកតាមាត្រាសាស្ត្រជាតិស្របច្បាប់ ដូចបានកំណត់ក្នុងឧបសម្ព័ន្ធ១ និងឧបសម្ព័ន្ធ២ នៃច្បាប់ស្តីពីមាត្រាសាស្ត្រ
- មានការបង្ហាញសមត្ថភាព អប្បបរមា និងអតិបរមា អំពីទម្ងន់ និង/ឬ រង្វាស់រង្វាល់នៃឧបករណ៍មាត្រាសាស្ត្រនោះ និង/ឬ ពាណិជ្ជនាម ឬ អាសយដ្ឋានផលិត។

**ប្រការ៨._**

ក្រោយពីមន្ត្រីមានសមត្ថកិច្ចនៃនាយកដ្ឋានទទួលបន្ទុក បានពិនិត្យវាយតម្លៃលើពាក្យស្នើសុំតាមបែបបទ និងនីតិវិធីដូចមានចែងក្នុងប្រការ៦នៃប្រកាសនេះរួចរាល់ហើយ ក្រសួងត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួន ទៅអ្នកស្នើសុំក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃយ៉ាងយូរនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលទទួលបានពាក្យស្នើសុំ។

ក្នុងករណីមិនយល់ព្រមតាមការស្នើសុំ ក្រសួងត្រូវឆ្លើយតបទៅអ្នកស្នើសុំ ដោយបញ្ជាក់ពីមូលហេតុឱ្យបានត្រឹមត្រូវ។

លិខិតអនុញ្ញាតនេះមានសុពលភាព ៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខា។

**ប្រការ៩._**

រាល់ការផ្ទេរ ការលក់នូវលិខិតអនុញ្ញាតនាំចូលឧបករណ៍មាត្រាសាស្ត្រ ត្រូវមានការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

ក្នុងករណីមានការពន្យាពេលនាំចូល អ្នកនាំចូលត្រូវធ្វើលិខិតស្នើសុំបន្តសុពលភាពជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបាន ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃផុតសុពលភាពនៃលិខិតអនុញ្ញាតនេះ។

**ប្រការ១០._**

នៅពេលឧបករណ៍មាត្រាសាស្ត្រ បាននាំចូលមកដល់កម្ពុជា (ទីកន្លែងស្តុក) អ្នកនាំចូលត្រូវតែជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មកក្រសួង ដើម្បីស្នើសុំមន្ត្រីមានសមត្ថកិច្ចចុះត្រួតពិនិត្យអង្កេតជាក់ស្តែង។

**ប្រការ១១._**

ប្រកាសលេខ ១៤១ ឧ.ថ.មមជ.ប្រក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពី នីតិវិធី និងបែបបទនៃការស្នើសុំលិខិតអនុញ្ញាតការនាំចូលឧបករណ៍មាត្រាសាស្ត្រ និងបទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធាននាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ គ្រប់អង្គភាពក្រោមឱវាទក្រសួង និងរូបវន្តបុគ្គល នីតិបុគ្គលដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

« *ដើម្បីជូនជ្រាប* »

- ដូចប្រការ១២

« *ដើម្បីអនុវត្ត* »

- ឯកសារ-កាលប្បវត្តិ